## Consoling someone



### បាត់បង់សត្វចិញ្ចឹម

ស្រីពេជ្រ៖ កុសល ម៉េចហ្នឹង? ដូចស្រងូតស្រងាត់ម៉េះ?
កុសល៖ ឆ្មាខ្ញុំ តាំងពីប៉ុន្មានថ្ងៃមុន ឈឺ។ ស៊ីអត់បាន ហើយចេះតែថ្ងូរ។ ដល់ព្រឹកមិញក្រោកឡើង វាងាប់បាត់។
ស្រីពេជ្រ៖ សត្វវាអីចឹងហើយ កុសល។ អាយុវាខ្លីជាងមនុស្ស អីចឹងវាត្រូវតែទៅមុនហើយ។ កុំពិបាកចិត្តអី កាត់ចិត្តទៅ។ វាក៏ឆាប់បានទៅចាប់ជាតិថ្មីដែរ។

### ប្រឡងធ្លាក់

ម្ដាយ៖ ម៉េចហើយកូន?
កូន៖ ធ្លាក់បាត់ហើយម៉ាក់។
ម្ដាយ៖ មិនអីទេ។ ប្រឡងទៅស្រុកក្រៅ មិនងាយឯណា។ គេធ្លាក់ម៉ាគំនរ។ ចាំប្រឡងលើកក្រោយទៀតទៅ។
កូន៖ ស្ដាយអំាម៉ាក់។ ខំប្រឡងជាប់ដល់សម្ភាសន៍ហើយ។
ម្ដាយ៖ ស្ដាយចេះតែស្ដាយហើយ តែធ្វើម៉េចបើអីចឹងហើយ។ មិនអីទេ នៅមានឱកាសផ្សេងៗទៀតដែរតាស។

| | |
|---|---|
| ស្រីពេជ្រ / កុសល | female / male Cambodian name |
| ដូចស្រងូតស្រងាត់ម៉េះ? | You seem sad – why? |
| ... បាត់ | already |
| ... អីចឹងហើយ | it's natural, that's what it should be, that's what it is |
| ទៅមុន | to go first = to die first |
| កុំ ... អី | don't ..., you'd better not ... |
| កាត់ចិត្តទៅ | move on! |
| ចាប់ជាតិ | to be reborn (usually implying that an animal will be reborn as a human) |
| ម៉ាគំនរ | spoken form of មួយគំនរ = a lot, plenty |
| អំា | spoken form of ណាស់ = very |

Copyright © 2018 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

| | |
|---|---|
| ស្ដាយចេះតែស្ដាយហើយ | of course, it’s disappointing |
| ធ្វើម៉េចបើអីចឹងហើយ | there’s nothing we can do about it |
| តាស | affirmative particle |

## Cultural notes

នៅពេលគេនិយាយប្រាប់អ្នកអំពីរឿងអកុសលរបស់គេ តើមានពាក្យអ្វីដែលបង្ហាញថាអ្នកសោកស្ដាយ ? នៅក្នុងភាសាខ្មែរ មិនមានឃ្លាស្មើនឹង “I’m sorry to hear about that” នោះទេ ប៉ុន្តែ ជាផ្លូវការ គេប្រើឃ្លាថា “សូមចូលរួមសោកស្ដាយផង” ឬ “សូមចូលរួមរំលែកទុក្ខផង”។ សម្រាប់ប្រតិកម្មភ្លាមៗនៅពេលសន្ទនាភាគច្រើនគេបង្ហាញទឹកមុខភ្ញាក់ផ្អើលនិងក្រៀមក្រំ ដោយលាន់មាត់ថា “អីចឹង ?” “ហ្នឹង(អំ) ?” “ម៉េចចឹង ?” “មានរឿងអី (ម៉េចបានអីចឹង) ?” ហើយសាកសួរអំពីដើមទងនៃហេតុការណ៍ដែលកើតឡើង។

| | |
|---|---|
| រឿងអកុសល | misfortune |
| សោកស្ដាយ | to be/feel sorry |
| ជាផ្លូវការ | formally |
| ប្រតិកម្ម | reaction |
| អីចឹង/ហ្នឹងអំ/ម៉េចចឹង ? | Really? |
| ដើមទង | beginning |

## Additional dialogue

កុសល៖ ចី ? ស្រីពេជ្រ ដូចអត់សប្បាយចិត្ត។

ស្រីពេជ្រ៖ ត្រូវគេស្ដីឲ្យ សប្បាយចិត្តម៉េចកើត ?

កុសល៖ បើយើងធ្វើខុស គេស្ដីឲ្យ យើងទទួលយក ហើយកែទៅ។ មានអ្នកណាដែលថាមិនដែលខុស។ បើខុសហើយ អត់មានអ្នកជួយប្រាប់ អាហ្នឹងបានពិបាក។ តែបើគេស្ដីឲ្យអត់មានហេតុផល យើងស្ដាប់ចូលត្រចៀកម្ខាងចេញត្រចៀកម្ខាងទៅ។ កុំខ្វល់ ហើយមិនបាច់យកខួរក្បាលទៅគិត ឬទៅឈឺចាប់ជាមួយទេ។

| | |
|---|---|
| ចី ? = មានរឿងអ្វី ? | What happened? |
| ស្ដីឲ្យ | to blame, to scold (here in a passive construction with ត្រូវ) |
| ... ម៉េចកើត ? | How can I [be] ...? |
| អាហ្នឹងបានពិបាក | that’s what we should be worried about |
| អត់មានហេតុផល | without a (good) reason |
| កុំខ្វល់ | don’t worry! |
| យកខួរក្បាលទៅគិត | to use the brain to think about it (disapproving meaning) |

Copyright © 2018 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.